ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ១០៦ រថ.បវប.ប្រក

# ប្រកាស

## ស្តីពីការកែសម្រួលប្រការ ៨ ១១ ១២ ១៥ និង១៧
## នៃប្រកាសលេខ ០០៩២ រថ.បវប.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥
## ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរ និងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជា ទៅក្រោមក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ ០៧.សរណន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ស្តីពីវិធានការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលាសិលា
- បានឃើញប្រកាសរួមលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ ១**.-

ប្រកាសនេះ មានគោលបំណងសម្រួលបន្ថែមនូវនីតិវិធីក្នុងការដាក់ពាក្យស្នើសុំនិងការចេញលិខិតអនុញ្ញាតផ្សេងៗដល់អាជីវករ ឬ ក្រុមហ៊ុនស្ថានីយឧស្ម័នឥន្ធនៈ ឬ ស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ ស្របតាមបទដ្ឋានគតិយុត្តឲ្យបានរហ័ស ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវ។

**ប្រការ ២**.-

ត្រូវបានកែសម្រួលប្រការ ៨ ១១ ១២ ១៥ និង១៧ នៃប្រកាសលេខ ០០៩២ រថ.បវប.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ដោយជំនួសខ្លឹមសារទាំងស្រុងតាមប្រការថ្មីដូចខាងក្រោម៖

**ប្រការ ៨** (ថ្មី).-

រាល់ពាក្យស្នើសុំទាំងអស់ ត្រូវដាក់នៅមន្ទីររ៉ែនិងថាមពលរាជធានី-ខេត្ត នៅរៀងរាល់ថ្ងៃធ្វើការ និងម៉ោងធ្វើការ ហើយមន្ទីររ៉ែនិងថាមពលរាជធានី-ខេត្ត ត្រូវបញ្ជូនសំណុំឯកសារស្នើសុំទាំងនេះឲ្យដល់ច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំនោះ។ មន្ត្រីដែលទទួលពាក្យស្នើសុំនៅមន្ទីររ៉ែនិងថាមពលរាជធានី-ខេត្ត ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ភាពពេញលេញនៃពាក្យស្នើសុំនីមួយៗ រួមទាំងសំណុំឯកសារពាក់ព័ន្ធដែលភ្ជាប់មកជាមួយ។ បើពិនិត្យឃើញថា សំណុំឯកសារ៖

ក. មានភាពពេញលេញ មន្ត្រីទទួលពាក្យត្រូវចេញសលាកបត្រទទួលពាក្យជូនអ្នកដាក់ពាក្យស្នើសុំ

ខ. មិនទាន់ពេញលេញ មន្ត្រីទទួលពាក្យត្រូវបដិសេធពាក្យស្នើសុំ ហើយណែនាំឲ្យអ្នកដាក់ពាក្យបំពេញបន្ថែមតាមបញ្ជីផ្ទៀងផ្ទាត់។

**ប្រការ ១១** (ថ្មី).-

បន្ទាប់ពីទទួលបានមតិយោបល់ពីនាយកដ្ឋានទទួលបន្ទុក និងអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល មានរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីសម្រេច ៖

ក. ឯកភាពតាមសំណើ ឬ

ខ. ឯកភាពតាមសំណើដោយមានលក្ខខណ្ឌ ឬ

គ. ស្នើឲ្យបំភ្លឺបន្ថែម ឬ តម្រូវឲ្យបុគ្គលស្នើសុំធ្វើការកែសម្រួលបំពេញបន្ថែម ឬ

ឃ. ធ្វើការបដិសេធចំពោះពាក្យស្នើសុំ ដោយមានមូលហេតុនៃការសម្រេច ជាលាយលក្ខណ៍អក្សរ។

**ប្រការ ១២** (ថ្មី).-

វិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានសុពលភាព ០២ (ពីរ) ឆ្នាំ។ ម្ចាស់ស្ថានីយ

ប្រេងឥន្ធនៈ ត្រូវមកដាក់ពាក្យស្នើសុំបន្ត សុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃ មុនពេលផុតកំណត់សុពលភាព នៅមន្ទីររ៉ែនិងថាមពលរាជធានី-ខេត្ត ហើយមន្ទីររ៉ែនិងថាមពលរាជធានី-ខេត្ត ត្រូវបញ្ជូនសំណុំឯកសារស្នើសុំទាំងនេះឲ្យដល់ច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំនោះ។

**ប្រការ ១៥** (ថ្មី).-

ម្ចាស់ស្ថានីយ ត្រូវមកដាក់ពាក្យស្នើសុំកែសម្រួល ឬ ពាក្យស្នើសុំផ្ទេរម្ចាស់ស្ថានីយប្រេងឥន្ធនៈ មុនកែសម្រួលស្ថានីយ ឬ មុនប្រគល់ស្ថានីយទៅម្ចាស់ថ្មី នៅមន្ទីររ៉ែនិងថាមពលរាជធានី-ខេត្ត ហើយមន្ទីររ៉ែនិងថាមពលរាជធានី-ខេត្ត ត្រូវបញ្ជូនសំណុំឯកសារស្នើសុំទាំងនេះឲ្យដល់ច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំនោះ។

**ប្រការ ១៧** (ថ្មី).-

ម្ចាស់ស្ថានីយប្រេងឥន្ធនៈ ដែលបានដាក់ពាក្យស្នើសុំលិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃការបង្កើតស្ថានីយ ឬ វិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយ ឬ បន្តសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយ ឬ កែសម្រួលស្ថានីយ ឬ ផ្ទេរម្ចាស់ស្ថានីយ ត្រូវបង់កម្រៃសេវាកម្មចំពោះការពិនិត្យពាក្យស្នើសុំនោះ តាមការកំណត់នៅក្នុងប្រកាសរួមលេខ១៤៥១ សហវ-ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ៣**.-

អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពល រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មីនា ឆ្នាំ ២០១៦*

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

<u>ចម្លងជូន:</u>

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ